ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតបន្ថែមគណនី មូលនិធិគន្ធបុប្ផាកម្ពុជា និង គណនី មូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ នៃប្លង់គណនេយ្យសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ១._**

ត្រូវបានបង្កើត÷

**១.**គណនី **មូលនិធិឥតទ្ធបុប្ផាកម្ពុជា** មានលេខសម្គាល់ ៤៤១២ ស្ថិតក្នុងជំពូក ប្រាក់បញ្ញើរបស់រដ្ឋនិងសម្ព័ហភាពសាធារណៈ មានលេខសម្គាល់ ៤៤

**២.**គណនី **មូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣** មានលេខសម្គាល់ ៤៤១៣ ស្ថិតក្នុងជំពូក ប្រាក់បញ្ញើរបស់រដ្ឋនិងសម្ព័ហភាពសាធារណៈ មានលេខសម្គាល់ ៤៤។

**ប្រការ២._**

ប្រព្រឹត្តិកម្មនៃគណនី÷

**១.**គណនី **មូលនិធិឥតទ្ធបុប្ផាកម្ពុជា** មានលេខសម្គាល់ ៤៤១២ បើកនៅរតនាគារកណ្ដាល និងប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលមូលនិធិដែលបានមកពីឧបត្ថម្ភធនពីថវិការដ្ឋ ឬ ពីប្រភពផ្សេងទៀត និងទឹកប្រាក់ចំណាយមូលនិធិសម្រាប់ចំណាយផ្សេងៗ ដោយបើកផ្ដល់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ។

គណនីមូលនិធិគន្ធបុប្ផាកម្ពុជាត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។ សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

**ការកត់ត្រា:**

**ឥណពន្ធ** : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

**ឥណទាន** : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលពីឧបត្ថម្ភធនពីថវិការដ្ឋ ឬ ពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើមូលនិធិ ដែលកំពុងមាននៅរតនាគារ។

**២.**គណនី **មូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣** មានលេខសម្គាល់ ៤៤១៣ បើកនៅរតនាគារកណ្ដាល និងប្រើប្រាស់សម្រាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលមូលនិធិដែលបានមកពីឧបត្ថម្ភធនពីថវិការដ្ឋ ឬ ពីប្រភពផ្សេងទៀត និងទឹកប្រាក់ចំណាយមូលនិធិសម្រាប់ចំណាយផ្សេងៗ ដោយបើកផ្ដល់ជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ។ គណនីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី។ សមតុល្យនៃគណនីនេះត្រូវយោងទៅការិយបរិច្ឆេទបន្ទាប់។

**ការកត់ត្រា:**

**ឥណពន្ធ** : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយជាសាច់ប្រាក់ ឬ មូលប្បទានបត្រ ឬ ដោយបង្វែរ

**ឥណទាន** : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលពីឧបត្ថម្ភធនពីថវិការដ្ឋ ឬ ពីប្រភពផ្សេងទៀត

**សមតុល្យ** : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើមូលនិធិ ដែលកំពុងមាននៅរតនាគារ។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤._**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានថវិកា
- អគ្គនាយកដ្ឋានរតនាគារជាតិ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ